N° 3
Reçu le 9-5-51
INDOCHINE FRANCAISE RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែមីនា លេខ ៣

ព. ស. ២៤៩៣ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

---

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |


ពុទ្ធសាសនានឹងគ្រឹស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតម៉ីគូត់) ....... លោក ភិយ - ប៊ុក ....... ១៦៣

ពន្លឺអាស៊ីទ្វីប (តមក) .......... លោក ភិយ - ប៊ុក ....... ១៦៩

ធម្មបរិយាយ ............ ព្រះគ្រូញាណលិខិត កៅ - ស៊ុម .. ១៧៧

**ផ្នែកអក្សរសាស្ត្រ**

ការបណ្ដុះនិស្ស័យ (តមក) ...... ព្រះមហាឧត្តមវង្សា ពុង - ប៉ម .. ១៨៥

សព្វថាភាំងប្រែជាខ្មែរ (តមក) ........ លោក ម៉ុញ - តាំត្រី ..... ១៩៣

រឿងព្រេងភូមា (តចប់) ......... — សាង - សាភ័ត ...... ១៩៨

រឿងសាមកុក (តមក) ........... — ទួ - កន ......... ២០៧

ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) .. — ឈឹម - ក្រសេម ..... ២២១

**កំណត់ទិនព្រឹត្តិការណ៍**

អនុស្សាវរីយ៍ព្រះមហាសន្និបាត (តចប់) ..... ពុទ្ធសាសនបណ្ឌិត្យ ....... ២២៥


---

មួយឆ្នាំមាន ១២ សៀវភៅ ថ្លៃជាវ ............. ១៤៥៛,០០

## ធម្មបរិយាយគាថា

*ព្រះគ្រូបញ្ញាលិខិត កៅ-ស៊ឹម សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់*

**ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃទី ២២ ខែកញ្ញា គ.ស. ១៩៥៣**

---

### នមត្ថុ រតនត្តយស្ស

*លំដាប់តទៅនេះ, សូមសំដែងធម្មទេសនា ជាធម្មបរិយាយផ្សាយតាមវិទ្យុ ដោយសេចក្ដីសង្ខេប ដើម្បីនឹងញុំាងទឹកចិត្តនៃសាធុជន ជាសប្បុរស អ្នកដែលមានសទ្ធានឹងសេចក្ដីជ្រះថ្លាក្នុងបវរពុទ្ធសាសនា ឲ្យចុះស៊ប់កាន់ធម៌ទេសនាតាមនិពន្ធគាថា ដូចតទៅនេះ :—*

យថាបិ នាម ជច្ចន្ធោ   នរោ អបរិណាយកោ
ឯកទា យាតិ មគ្គេន   ឧម្មគ្គេនាបិ ឯកទា
សំសារេ សំសរំ ពាលោ   តថា អបរិណាយកោ
ករោតិ ឯកទា បុញ្ញំ   អបុញ្ញម្បិ ឯកទា
យទា ច ញត្វា សោ ធម្មំ   សច្ចានិ អភិសមេស្សតិ
តទា អវិជ្ជូបសមា   ឧបសន្តោ ចរិស្សតិ ។

*ប្រែថា : "មនុស្សខ្វាក់អំពីកំណើត (ត្រាច់ចរលើផែនដី) បើមិនមាន គេដឹកដៃនាំមុខទេ ជួនដើរត្រង់ផ្លូវ ជួនដើរខុសផ្លូវ យ៉ាងណាមិញ ;*

មនុស្សពាលនៅតែល្ងង់ទៅ  កាលចរត្រាច់ត្រាត់ទៅក្នុងកាលវដ្ដសង្សារ បើមិនមានបណ្ឌិតដឹកនាំមុខទេ ជួនធ្វើបុណ្យ ជួនធ្វើបាប ក៏យ៉ាងនោះដែរ; លុះតែមនុស្សពាលនោះ យល់ធម៌ច្បាស់លាស់ ត្រាស់ដឹងនូវអរិយសច្ច ៤ ប្រការពេលណា ទើបជាបុគ្គលប្រព្រឹត្តសន្តិសុខស្ងប់ស្ងាត់ពេលនោះ ព្រោះបានរម្ងាប់នូវអវិជ្ជា” ។

គតិនេះ ទើបអធិប្បាយព្រះពុទ្ធភាសិតខាងលើនេះតទៅ :—

ព្រះសម្ពុទ្ធវិសុទ្ធិគុណទ្រង់ប្រាប់ច្បាស់ថា ពួកសត្វនិករទាំងឡាយដែលលិចលង់នៅក្នុងអំណាចអវិជ្ជាគ្រោតអរក្នុងសង្សារវដ្ដ តែងមានគំនិតត្រិះរិះពិចារណាយល់ខ្វេង គាត់តែងត្រៀងធ្វើជាបុណ្យក៏មាន ជាបាបក៏មាន មិនប្រាកដ ដូចមនុស្សខ្វាក់ដើរព្រាវលើផែនដី ជួនចំផ្លូវ ជួនខុសផ្លូវ ពានទៅលើទំនួល ទំនាប មិនរាបមិនស្មើ ជាហេតុឲ្យបានសេចក្ដីទុក្ខលំបាកច្រើន ។ ឯសព្វសត្វក្នុងលោកសន្និវាសនេះ សុទ្ធសឹងតែប្រាថ្នារកសេចក្ដីសុខចំរើនគ្រប់ៗគ្នា តែជួនពារពានទៅលើទុក្ខក៏មានជួនពារពានទៅលើសុខក៏មាន ដោយហេតុមកពីគំនិតយល់ត្រូវ និងយល់ខុស, កាលបើគិតត្រូវ យល់ត្រូវ ប្រកបកិច្ចការងារត្រូវ ក៏បានសេចក្ដីសុខចំរើន, បើគិតខុស យល់ខុស ប្រកបកិច្ចការងារខុស ក៏បានសេចក្ដីទុក្ខមិនបានចំរើន ព្រោះមកពីមានប្រាជ្ញា និងខ្វះប្រាជ្ញាជាបុព្វហេតុ ។

គំនិតមនុស្សដែលយល់ខ្វេង មិនត្រូវតាមហេតុ ស្មានហើយធ្វើយកគ្មានទីពឹងចំណេះវិជ្ជាអ្វីយកមកពិចារណាពិនិត្យពិច័យឲ្យច្បាស់លាស់ជា

មុនសិន ស្រាប់តែប្រកបកិច្ចការងារនោះ ធ្វើទៅតាំងស្នាន កប់អាន គោរពបូជាទៅតាំងបំពាន ក្នុងពេលដែលខ្លួនបានសេចក្ដីទុក្ខលំបាក មាន ខ្លះទៅបន់ស្រន់នៅទីកន្លែងណាមួយ មានដើមឈើជាដើម ដោយយល់ ខុសថា ៖ ដើមឈើនោះៗឲ្យសិរីសួស្ដីមង្គលដល់ខ្លួន និងគ្រួសាររបស់ ខ្លួន ៗ មិនតែប៉ុណ្ណោះថែមទាំងធ្វើទេវដ្ឋានអាស្រមខ្ទម-ពេងសាងទេវរូប ជារូបអ្នកតាឃ្លាំងមឿងប្រចាំស្រុក រូបដុំថ្មដាក់ដំកល់ក្នុងទេវដ្ឋាននោះៗ សម្រាប់ទុកគោរពកប់អានបូជាកោតខ្លាច គ្រប់ស្រុកគ្រប់ភូមិរាល់ឆ្នាំ ពួក អ្នកស្រុកទាំងប្រុសស្រីចាស់-ក្មេងប្រជុំគ្នាទៅបូជាយញ្ញ ហៅថាឡើង អ្នកតា មានចាប់សត្វក្របី-ស្វា-មាន់-ទា និងផ្អកជាដើម តាមចំណូល អ្នកតាយកទៅបូជា ដោយធ្វើពិធីសម្លាប់ពន្លាត់ស្បែកដោតក្ដាងត្រដាង ថ្វាយនៅមុខអ្នកតា ផឹកស្រា-ស៊ីសាច់-សែនពែងផ្តិលស្រា-អុជផាវហោ ករញ្ញៀវ-លេងភ្លេង-បញ្ចាន់រូបអារក្ស សូមសិរីសួស្ដីតបៈតេជៈអំពី អ្នកតាថា ៖ សូមធ្វើស្រែស្រូវអង្ករ-ល្ង-សណ្ដែក-ដំបែក-អំពៅក្នុងឆ្នាំ នេះឲ្យបានផលផ្លែបរិបូណ៌, សូមឲ្យទឹកភ្លៀងធ្លាក់ចុះមកបរិបូណ៌, សូមឲ្យ សប្បាយដល់គ្រួសារគ្រប់ៗគ្នាកុំឲ្យវេទនា ដូចេះក៏មាន ៗ ជួនកាលប្រើ គំនិតព្រាវទៅលើវត្ថុអាកម ដែលជាទីគួរជ្រះថ្លាគោរពបូជារបស់អ្នកកាន់ ព្រះពុទ្ធសាសនា ថាជាទីនៅអាស្រ័យនៃខ្មោចល្បាក់សា បិសាចបំបួរជួរ ឬយាយទេព្យ ដែលធ្វើខ្លួននិងគ្រួសារឲ្យបានទុក្ខលំបាក ហើយក៏លន់តួ

ទោសបៃរបង់ប្អូនស្អូនសូមសេចក្តីសុខសប្បាយដល់ខ្លួននឹងគ្រួសារ សូមលើនគ្រឿងថ្វាយបូជាបាយសីស្លាធរ - ស្លាធម - បូជាចេក - ថ្វាយស្រា - ថ្វាយមាន់ - ថ្វាយទា គោរក្បាលថ្វាយ ទឹងបួស ១ សំពាំងដំរីថ្វាយដូច្នេះក៏មាន ៗ

ហេតុនេះយើងជាតិមនុស្សបុថុជ្ជន ក្នុងពេលដែលបានទុក្ខលំបាក ហើយ កុំគាលប្រញាប់ដាក់ទោសទៅលើខ្មោចល្បក់សាចបួរជួរនោះពេក គួរគិតពិចារណាការកឲ្យឃើញហេតុផលសិនសឹមធ្វើទើបល្អ ៗ ឯចង្រៃ អពមង្គលទាល់ទុក្ខលំបាកនោះ មិនមែនដើមឈើជុំថ្វឲ្យទេ តាមពិត នោះគឺអវិជ្ជាធ្វើឲ្យបានទុក្ខវេទនា ៗ

មនុស្សអ្នកជឿហេតុខាងក្រៅ បង់សេចផលកម្មរបស់ខ្លួនពោល នឹងឲ្យឈ្មោះថាជាមនុស្សគិតត្រូវ យល់ត្រូវ ធ្វើការងារត្រូវឯណាកើត? ធ្វើម្តេចនឹងបានសេចក្តីសុខចំរើន? ព្រោះជាអ្នកកាន់ប្រាជ្ញ លុះក្នុងអំណាច អវិជ្ជាគ្របសង្កត់ជាប់ ប្រៀនប្តូលចិត្តផ្សំថា: បើមនុស្សយើងបរិភោគវត្ថុយ៉ាងណា ខ្មោចប្អូទេវតា ក្រើន ក៏គង់ចូលចិត្តបរិភោគវត្ថុយ៉ាងនោះដែរ; ត្បូយ៉ាងគេនាំគ្នាកប់គាងធ្វើពិធីបូជាក្រើន គឺគេនាំគ្នាជីករណ្តៅនៅទីកន្លែងណាមួយ ហើយយកក្រើនទៅបង្កាត់ក្នុងរណ្តៅនោះឲ្យឆេះសន្ធោសន្ធៅឡើង ទើបយកសត្វតិរច្ឆាន ឬមនុស្សទៅសម្លាប់សំឡេះយកសាច់ទំលាក់ចង់ទៅក្នុងគំនរក្រើនឲ្យក្រើនបរិភោគសាច់នោះ ដើម្បីសូមសុខសួស្តីឲ្យកើតឡើងដោយកម្មសិទ្ធនេះ ៗ

ព្រះសម្ពុទ្ធទ្រង់បានប្រាប់ច្បាស់ថា ពួកសត្វ នាំគ្នាធ្វើពលិកម្មបូជាកប់ កាន់នូវទេវរូបនឹងការបូជាភ្លើងយ៉ាងនេះ ដោយដើរផ្លូវខុសទាំងនឹងមិនសមហេតុផលទេ ទើបទ្រង់ប្រែនយោបាយផ្លាស់ផ្លូវកម្មសិទ្ធរបស់សត្វទាំងនោះ ទ្រង់ដឹកនាំផ្លូវជាធម្មសិទ្ធដោយសំដែងប្រាប់ពលិកម្ម ៥ យ៉ាង ជាគ្រឿងបំភ្លឺឲ្យផ្លាស់គំនិតឈ្លើងយល់ខុសនោះ ទៅជាគំនិតត្រូវវិញ ។ ឯពលិកម្ម ៥ នោះដូចតទៅនេះ :

១ – **ញាតិពលិ** = សង្គ្រោះញាតិសន្តានដែលរស់នៅ,

២ – **អតិថិពលិ** = ទទួលភ្ញៀវដែលមកដល់ទីលំនៅខ្លួន,

៣ – **បុព្វប្បេតពលិ** = ធ្វើបុណ្យឧទ្ទិសផលបញ្ជូនទៅបុព្វបុរស, មានមាតាបិតាជាដើម ដែលចែកឋានទៅហើយ,

៤ – **រាជពលិ** = បង់ពន្ធដារជូនរាជការផែនដី,

៥ – **ទេវតាពលិ** = ធ្វើបុណ្យឧទ្ទិសផលដល់ពួកទេវតា ។

ពលិកម្ម ៥ នេះហើយ ជាផ្លូវនាំឲ្យបានសេចក្ដីសុខចំរើនទាំងលោកនេះនឹងលោកខាងមុខ ជាដំណើរចៀសវាងនឹងពីផ្លូវគោតល្ងង់ខ្លៅកាន់ជឿរបស់មនុស្សដែលឥតគំនិតគតប្រាជ្ញាមិនបានការនោះ ។ ។

គំនិតដែលកាន់ជឿយ៉ាងនេះមុខជានឹងជឿដោយគៀរគ្រឡប់សាមកលើខ្លួនអ្នកធ្វើវិញមិនខាន សមដូចព្រះសម្ពុទ្ធទ្រង់ពោលទុកមកថា :

បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

" អ្នកណាប្រាថ្នាសុខចំពោះខ្លួន ដោយការបំពេញទុក្ខទៅលើអ្នកដទៃ អ្នកនោះឈ្មោះថាជាប់ចំពាក់ខ្វាក់ដោយពៀរ រមែងដោះខ្លួនមិនរួចផុតស្រឡះចាកពៀរឡើយ " ។

ការទំលាក់ទុក្ខស្រោចទោសទៅលើអ្នកឯទៀតនោះ គួរប្រាប់ថា : ត្រឡប់ឲ្យផលសងសឹកមកខ្លួនវិញ ត្រូវតាមដំណើរដើមដែលខ្លួនធ្វើទៅលើគេ ឬក៏ឲ្យផលខុសពីស្ថានដើម តែត្រូវគេពិន័យជាបទអាជ្ញា ត្រូវជាប់គុកច្រវាក់ ឬក៏ក្លាយឲ្យផលត្រូវទទួលវេទនាដ៏ក្រោះថ្នាក់ ១០ យ៉ាងផ្ទួនបណ្តាលឡើង គឺ: ១ – ត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង ; ២ – ត្រូវវិនាសសាបសូន្យចាកយសស័ក្តិ ; ៣ – ត្រូវបែកធ្លាយសរីរៈកងកាយ ; ៤– ត្រូវមានជម្ងឺឈឺជាទម្ងន់ ; ៥ – ត្រូវបានសេចក្តីក្រឡកចិត្តឆ្កួត ; ៦ – ត្រូវស្តេចរឹបជាន់ ; ៧ – ត្រូវគេចោលបង្កាច់យ៉ាងអាក្រក់ ; ៨ – ត្រូវនិកសព្រាត់ប្រាសចាកពួកញាតិសន្តាន ; ៩ – ត្រូវហិនហោចខូចខាតទ្រព្យសម្បត្តិ ; ១០ – ត្រូវភ្លើងឆេះផ្ទះ (អន្ទះបាញ់បំផ្លាញអ្នកនោះ) លុះបែកធ្លាយកងកាយទៅ អ្នកដែលមានគំនិតយល់ឆ្វេងឥតប្រាជ្ញា អវិជ្ជាគាត់តែងគ្រឿងផ្សំស្មារឲ្យទៅកើតក្នុងកន្លែងនរក ។ នេះហើយជាផលក្លាយខុសចាកស្ថានដើម ជាផលដែលដេញទាន់ជាន់កែងដូចសំដែងមកនេះ ។

ធម្មតាមនុស្សឆោតល្ងង់ប្រកាន់ទិដ្ឋិ ទំលាក់ក្រោញគំនិតអាក្រក់ គំនិតព្យាបាទខឹងប្រទូស្តអ្នកដទៃ តែងមិនរួចផុតអំពីចំណង ៧ យ៉ាងជាគ្រឿងចងផ្ចង់របស់អវិជ្ជា ឲ្យជាប់កើតស្លាប់ត្រៀបត្រាក្នុងវដ្តសង្សារនេះគឺ

១ — **រាគពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយកាមគុណ ៥ គឺឲ្យសម្បូណ៌ដោយរូប-សំឡេង-ក្លិន-រស-សម្ផស្ស ;

២ — **ទោសពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយបដិឃៈ គឺឲ្យសម្បូណ៌ដោយទោសៈ សេចក្ដីក្រោធពិរោធខឹងវាយដំប្រទាក់ កាប់សម្លាប់គ្នា បៀតបៀនគ្នា ព្យាបាទគ្នាទាល់តែវិនាសរៀងខ្លួន ;

៣ — **មោហពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយមោហៈ គឺឲ្យសម្បូណ៌ដោយសេចក្ដីវង្វេង កាន់ច្រឡំ ឆោតល្ងង់ទៅ ;

៤ — **ទិដ្ឋិពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយទិដ្ឋិ គឺឲ្យសម្បូណ៌តែខាងឃើញខុស យល់ខុសប្រកាន់ខុសថាជាត្រូវ ថាជាខុសដោយផ្លូវសស្សតទិដ្ឋិ គឺយល់ឃើញទៀងថា: សត្វលោកដែលធ្លាប់កើតយ៉ាងណា ស្លាប់ទៅវិញក៏ទៅកើតជាយ៉ាងនោះដដែលមិនប្រែប្រួល, ឧច្ឆេទទិដ្ឋិ យល់ឃើញថា : សត្វលោកស្លាប់ហើយសូន្យ មិនមានអ្វីនាំឲ្យទៅកើតទៀតទេ ;

៥– **មានពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយមានៈ គឺឲ្យសម្បូណ៌ដោយរឹងត្អឹងលើកខ្លួនឲ្យខ្ពស់ប្រសើរជាងគេ មិនព្រមជឿស្តាប់បង្គាប់អ្នកណា ចចេសយកឈ្នះតែម្នាក់ឯង ;

៦– **កិលេសពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយកិលេសជាគ្រឿងរឹតរុំ គឺឲ្យសម្បូណ៌ដោយសំយោជនកិលេសទាំង ១០ ដែលធ្វើចិត្តសត្វឲ្យសៅ-ហ្មង វិលស្លាប់វិលកើតក្នុងវដ្តទុក្ខ ;

៧– **ទុច្ចរិតពន្ធនៈ** អវិជ្ជាចងផ្ចង់ដោយទុច្ចរិតទាំង ៣ គឺឲ្យសម្បូណ៌ដោយសេចក្តីប្រព្រឹត្តិអាក្រក់ ដោយកាយ-វាចា-ចិត្ត ។

ភាពមនុស្សពាល ដែលអវិជ្ជាចងផ្ចង់ដោយចំណងទាំង ៧ នេះ តែងបានសេចក្តីវិនាស សេចក្តីទុក្ខ ហេតុនោះ សាធុជនអ្នកដែលប្រាថ្នា សេចក្តីសុខចំរើន គួរខ្វាចចៀសវាងឲ្យផុតកុំឲ្យជួបប្រទះនឹងចំណងទាំងនេះ ។ សំដែងមកក្នុងធម្មបរិយាយកថាដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា សុទ្ធី បប្បោន្តុ សាធវោ ។**

សូមសាធុជនអ្នកស្តាប់ធម៌ទាំងឡាយ (ដែលផ្សាយតាមវិទ្យុនេះ) ជនណាដែលដល់ហើយនូវទុក្ខ សូមកុំឲ្យមានទុក្ខ, ជនណាដែលដល់ហើយនូវសេចក្តីភ័យ សូមកុំឲ្យមានភ័យ, ជនណាដែលដល់ហើយនូវសេចក្តីសោក សូមកុំឲ្យមានសោក, សូមឲ្យបានសម្រេចនូវសេចក្តីស្អាតបរិសុទ្ធគ្រប់ៗគ្នាឡើង ។